សម្រាប់ការចេញផ្សាយបន្ទាន់

# ផែនទីបង្ហាញផ្លូវស្តីពីការអនុវត្តដំណើរការពិគ្រោះយោបល់ជាមុន ដែលមានរយៈពេលប្រាំមួយខែ សម្រាប់គម្រោងប៉ាក់ឡាយ បានទទួលការឯកភាព

**ទីក្រុងវៀងចន្ទ ប្រទេសឡាវ ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៨** – នៅថ្ងៃនេះ ស្ថាប័នអភិបាលកិច្ចកម្រិតខ្ពស់នៃគណៈកម្មការទន្លេមេគង្គ (MRC) បានអនុម័តលើផែនទីបង្ហាញផ្លូវ ស្តីពីការអនុវត្តដំណើរការពិគ្រោះយោបល់ជាមុន ដែលមានរយៈពេលប្រាំមួយខែ សម្រាប់សំណើគម្រោងវារីអគ្គិសនីប៉ាក់ឡាយ (Pak Lay) ក្នុងអំឡុងកិច្ចប្រជុំប្រចាំឆមាសរយៈពេលពីរថ្ងៃ ដែលធ្វើឡើងនៅក្រុងវៀងចន្ទ។

គណៈកម្មការចម្រុះ (Joint Committee) របស់ MRC ដែលមានសមាជិកជាតំណាងនៅកម្រិតប្រធាននាយកដ្ឋានមកពីប្រទេសជាសមាជិកទាំងបួនគឺ កម្ពុជា ឡាវ ថៃ និងវៀតណាម បានចាប់ផ្តើមកិច្ចប្រជុំរបស់ខ្លួនកាលពីថ្ងៃម្សិលមិញ ដើម្បីពិភាក្សាលើបញ្ហាពាក់ព័ន្ធនឹងការគ្រប់គ្រង ការរៀបចំ និងកិច្ចសហប្រតិបត្តិការ ក៏ដូចជា បញ្ហាគោលនយោបាយ និងយុទ្ធសាស្ត្រ។ គណៈកម្មការចម្រុះនេះមានភារៈកិច្ចអនុវត្តសេចក្តីសម្រេច និងគោលនយោបាយ ដាក់ចេញដោយក្រុមប្រឹក្សា (Council) របស់ MRC ដែលជាស្ថាប័នធ្វើសេចក្តីសម្រេចចិត្តកម្រិតខ្ពស់បំផុតរបស់គណៈកម្មការនេះ។

ផែនទីបង្ហាញផ្លូវដែលត្រូវបានអនុម័តនេះ បង្ហាញពីសកម្មភាព និងចំណុចដៅសំខាន់ៗ ក្នុងទម្រង់ជាផែនការសកម្មភាព ដែលត្រូវអនុវត្តក្នុងដំណើរការទាំងមូល ដោយផ្តោតសំខាន់លើកិច្ចពិគ្រោះយោបល់ជាមួយនឹងតួអង្គពាក់ព័ន្ធ។ វេទិការថ្នាក់តំបន់ជាមួយតួអង្គពាក់ព័ន្ធចំនួនពីរ និងកិច្ចប្រជុំចែករំលែកព័ត៌មានជាច្រើនតាមប្រទេសនីមួយៗ ដែលសុទ្ធតែមានគោលបំណងធ្វើការពិភាក្សា និងប្រមូលចងក្រងព័ត៌មានអំពីសេចក្តីព្រួយបារម្ភសមស្របនានា នឹងត្រូវរៀបចំឡើងក្នុងអំឡុងដំណើរការពិគ្រោះយោបល់ជាមុននេះ។

លោក តែ ណាវុធ (Te Navuth) ប្រធានគណៈកម្មការចម្រុះ មានប្រសាសន៍ថា "សាធារណជនដែលពាក់ព័ន្ធ ត្រូវបានលើកទឹកចិត្តឱ្យចូលរួមក្នុងវេទិកាពិគ្រោះយោបល់របស់ MRC និងកិច្ចប្រជុំចែករំលែកព័ត៌មាននៅតាមប្រទេស ក្នុងអំឡុងដំណើរការពិគ្រោះយោបល់ ដើម្បីលើកឡើងពីការព្រួយបារម្ភរបស់ខ្លួន អំពីគម្រោងប៉ាក់ឡាយ។ វេទិកា និងកិច្ចប្រជុំទាំងនេះ គឺជាច្រកដែលអ្នកអាចលើកឡើងពីការព្រួយបារម្ភ និងទទួលបានការឆ្លើយតប ដើម្បីប្រយោជន៍អាងទន្លេ និងប្រជាពលរដ្ឋរបស់យើង"។

លោកបានបន្តថា "កិច្ចពិគ្រោះយោបល់ជាមុននេះ មិនមែនជាយន្តការដែលល្អឥតខ្ចោះនោះឡើយ ប៉ុន្តែវាជាវេទិកា ល្អបំផុតដែលយើងមាន"។

ដូចបញ្ជាក់ក្នុងផែនទីបង្ហាញផ្លូវ ក្នុងអំឡុងដំណើការពិគ្រោះយោបល់ជាមុននេះ នឹងមានការចុះទៅពិនិត្យទីតាំងគម្រោង គ្រោងនឹងធ្វើនៅចុងខែ តុលា ឆ្នាំ ២០១៨ ជាផ្នែកមួយនៃកិច្ចប្រជុំលើកទីពីរ នៃក្រុមការងារគណៈកម្មការចម្រុះ (Joint Committee Working Group) របស់ MRC ដែលទទួលបន្ទុកពិគ្រោះយោបល់ជាមុនសម្រាប់គម្រោងប៉ាក់ឡាយ។ ក្រុមការងារនៃគណៈកម្មការចម្រុះ គឺជាស្ថាប័នផ្តល់ប្រឹក្សាដល់គណៈកម្មការចម្រុះរបស់ MRC ដែលមានសមាជិកជាតំណាងបច្ចេកទេសជាន់ខ្ពស់ មកពីប្រទេសជាសមាជិកទាំងបួន។

កិច្ចពិគ្រោះយោបល់ជាមុនជាផ្លូវការរបស់គម្រោងប៉ាក់ឡាយ គ្រោងនឹងបញ្ចប់នៅចុងខែ មីនា ឆ្នាំ ២០១៩។ ប៉ុន្តែ កិច្ចពិគ្រោះយោបល់នេះ អាចនឹងត្រូវបន្ថែមពេលវេលា ប្រសិនបើមានសំណើរពីគណៈកម្មការចម្រុះ។

នៅក្នុងកិច្ចប្រជុំនេះផងដែរ ក៏មានការលើកឡើងពីបញ្ហា ដែលនៅសេសសល់សំខាន់ៗមួយចំនួន ដូចជា ផែនការសកម្មភាពរួមសម្រាប់គម្រោងវារីអគ្គិសនីប៉ាក់បេង (Pak Beng) របាយការណ៍ត្រួតពិនិត្យឡើងវិញ ស្តីពីការផ្លាស់ប្តូរការរៀបចំគម្រោងសាយ៉ាបូរី (Xayaburi) ។ល។

ផែនការសកម្មភាពរួម រៀបរាប់ពីដំណើរការក្រោយការពិគ្រោះយោបល់ជាមុន សម្រាប់គម្រោងប៉ាក់បេង និងដាក់ចេញនូវយន្តការសម្រាប់បន្តទទួលព័ត៌មានត្រលប់ ដោះដូរទិន្នន័យ និងការចែករំលែកចំណែះដឹងរវាងក្រុមហ៊ុនអភិវឌ្ឍន៍ និងប្រទេសឡាវ និងរវាង MRC និងតួអង្គពាក់ព័ន្ធនានា ពាក់ព័ន្ធនឹងការរៀបចំ ការសាងសង់ និងប្រតិបត្តិការដែលកំពុងបន្តរបស់គម្រោងនេះ។ គណៈកម្មការចម្រុះទទួលព័ត៌មានថា កម្ពុជា ថៃ និងវៀតណាម បានផ្តល់សេចក្តីអនុម័តដល់សំណៅចុងក្រោយនៃផែនការសកម្មភាពរួមនេះហើយ ដោយឡែកប្រទេសឡាវ នៅកំពុងធ្វើការពិនិត្យមើលសំណៅចុងក្រោយនេះនៅក្នុងប្រទេសរបស់ខ្លួននៅឡើយ។

របាយការណ៍ត្រួតពិនិត្យឡើងវិញ ស្តីពីការផ្លាស់ប្តូរការរៀបចំគម្រោងសាយ៉ាបូរី គឺជាលទ្ធផលនៃការសិក្សា ដែលធ្វើឡើងដោយលេខាធិការដ្ឋាន MRC ដើម្បីធ្វើការកំណត់ថា តើអនុសាសន៍ដែលបានពីរបាយការណ៍ពិនិត្យបច្ចេកទេសលើគម្រោងសាយ៉ាបូរី ដែលជាផ្នែកមួយនៃកិច្ចពិគ្រោះយោបល់ជាមុន ដែលផ្តល់ដោយលេខាធិការដ្ឋាន MRC ត្រូវបានយកទៅធ្វើការពិចារណាក្នុងការកែសម្រួល ការរៀបចំគម្រោងសាយ៉ាបូរី ដែរឬទេ។ ដូចគ្នានឹងផែនការសកម្មភាពរួមសម្រាប់គម្រោងវារីអគ្គិសនីប៉ាក់បេងផងដែរ កម្ពុជា ថៃ និងវៀតណាម បានឯកភាពលើសំណៅបច្ចុប្បន្ននៃរបាយការណ៍ពិនិត្យឡើងវិញ ខណៈពេលដែលប្រទេសឡាវ នៅកំពុងធ្វើការពិភាក្សាជាមួយស្ថាប័នពាក់ព័ន្ធរបស់ខ្លួននៅឡើយ។

សមាជិកនៃគណៈកម្មការចម្រុះ ក៏បានឯកភាពជាគោលការណ៍លើធម្មនុញ្ញនៃគណៈកម្មការសវនកម្ម ដែលជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងរបស់ MRC ដើម្បីបង្កើតគណៈកម្មការសវនកម្ម របស់ខ្លួន។ គណៈកម្មការសវនកម្ម ដែលមានសមាជិកជាអ្នកជំនាញបច្ចេកទេសមកពីប្រទេសជាសមាជិកទាំងបួន មានភារៈកិច្ចជួយដល់គណៈកម្មការចម្រុះ ក្នុងការបំពេញការទទួលខុសត្រូវអភិបាលកិច្ច និង

ការត្រួតពិនិត្យពាក់ព័ន្ធនឹងរបាយការណ៍ហិរញ្ញវត្ថុ ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ប្រព័ន្ធគ្រប់គ្រងហានិភ័យ និង មុខងារសវនកម្មផ្ទៃក្នុងនិងក្រៅ របស់គណៈកម្មការនេះ។

ការផ្តល់ការឯកភាពបច្ចុប្បន្នដល់ធម្មនុញ្ញនេះ នឹងត្រួយត្រាយផ្លូវឱ្យ MRC បង្កើតគណៈកម្មការសវនកម្មនេះ ដែលបន្ទាប់មក នឹងត្រូវទទួលបានការឯកភាពពីគណៈកម្មការចម្រុះ។កិច្ចប្រជុំដែលបញ្ចប់នៅថ្ងៃទីនេះ ក៏ធ្វើការពិភាក្សាពីបញ្ហាសំខាន់ៗជាច្រើនផ្សេងទៀត ដូចជាសកម្មភាពតាមដានបន្តលើសេចក្តីប្រកាសទីក្រុងសៀមរាប វឌ្ឍនភាពនៃការពិនិត្យឡើងវិញ និងការធ្វើបច្ចុប្បន្នភាព យុទ្ធសាស្ត្រអភិវឌ្ឍន៍វារីអគ្គិសនីប្រកបដោយចីរភាព សម្រាប់តំបន់អាងទន្លេងមេគង្គ ក្រោម និងការបញ្ចប់គោលការណ៍ណែនាំស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន។

គណៈកម្មការទន្លេមេគង្គ ក៏នឹងរៀបចំវេទិកាថ្នាក់តំបន់ជាមួយនឹងអ្នកពាក់ព័ន្ធលើកទីមួយស្តីពីគម្រោងប៉ាក់ឡាយ នៅថ្ងៃទី ២០-២១ ខែកញ្ញា ឆ្នាំ ២០១៨ ក្នុងទីក្រុងវៀងចន្ទ។

## កំណត់សម្គាល់សម្រាប់និពន្ធនាយកៈ

គណៈកម្មការទន្លេមេគង្គ គឺជាស្ថាប័នអន្តររដ្ឋាភិបាល ដែលមានតួនាទីជំរុញលើកកម្ពស់កិច្ចពិគ្រោះយោបល់ និងកិច្ចសហប្រតិបត្តិការថ្នាក់តំបន់នៅក្នុងតំបន់អាងទន្លេមេគង្គខ្សែទឹកខាងក្រោម ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៩៥ ផ្អែកទៅតាមកិច្ចព្រមព្រៀងទន្លេមេគង្គ រវាងប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម។ ស្ថាប័ននេះ បំពេញតួនាទីជាវេទិកាថ្នាក់តំបន់សម្រាប់ការទូតទឹក ក៏ដូចជា ជាមជ្ឈមណ្ឌលប្រមូលផ្តុំចំណេះដឹងអំពីការគ្រប់គ្រងធនធានទឹក ដើម្បីការអភិវឌ្ឍន៍តំបន់នេះ ប្រកបដោយចីរភាព។

**-ចប់-**


## សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងៈ

លោក មាស សុភក្ត្រ

មន្ត្រីទំនាក់ទំនងជាមួយអ្នកសារព័ត៌មាន

អ៊ីម៉ែល៖ sopheak@mrcmekong.org

ទូរសព្ទ៖ +856-21-263263 ភ្ជាប់បន្ត 4070

ទូរសព្ទដៃ៖ +856-20-92479737


###